ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៨៦/១៨-រូស៊ីង ហ្គាំម៉េន (សាខាទី១)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន រូស៊ីង ហ្គាំម៉េន (សាខាទី១)**

អាសយដ្ឋាន ៖ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៣០ ៥០១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

- លោក ជូ ចាន់ស័ក ប្រធានការិយាល័យរដ្ឋបាលក្រុមហ៊ុន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន រូស៊ីង ហ្គាំម៉េន (សាខាទី១)**

អាសយដ្ឋាន ៖ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥០៤ ១៥៤/០១៧ ៣៧៦ ៨៨០ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការ ៖

១- លោក ស៊ាង យ៉ូត មន្ត្រីច្បាប់នៃសម្ព័ន្ធសហជីព (CCAWDU)

២- លោក អ៊ិន សុខរិទ្ធ មន្ត្រីច្បាប់នៃសម្ព័ន្ធសហជីព (CCAWDU)

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនទទួលយកកម្មករនិយោជិតដែលក្រុមហ៊ុនបានបញ្ឈប់ ចូលធ្វើការងារនៅកន្លែងដដែលវិញ និងសងរំលឹកប្រាក់ឈ្នួល ចាប់ពីថ្ងៃក្រុមហ៊ុនបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការងារវិញ។ ដោយឡែកភាគី និយោជកបានបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលយកពួកគាត់ឱ្យចូលធ្វើការវិញបានទេ ព្រោះកិច្ចសន្យាការងាររបស់ពួកគាត់ដល់កាលកំណត់ ហើយម្យ៉ាងទៀត ក្រុមហ៊ុនគ្មានការបញ្ជាទិញ។ ក្រុមហ៊ុនបានទូទាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនពួកគាត់តាមច្បាប់ស្តីពីការងាររួចហើយ។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនសុំឱ្យអ្នកផ្សះផ្សាដោះស្រាយសំណុំរឿងនេះ ទៅជាវិវាទបុគ្គលវិញ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន រូ ស៊ីង ហ្គាម៉ែន (សាខាទី១) លេខ ១០៥៨ ក.ប/អក/វក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ៤កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨ ស្តីពីការទាមទារសុំឱ្យជួយអន្តរាគមន៍ករណីក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន រើសអើងសហជីព និងបានបញ្ឈប់កម្មករនិយោជិតជាបន្តបន្ទាប់។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ និងធ្វើការ

THE ARBITRATION COUNCIL

ផ្សះផ្សាវិវាទនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជា ចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមរយៈរបាយការណ៍ ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) លេខ ១០៥៨ ក.ប/អក/វក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ១ ចំណុចនេះ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ២ និង ០០ នាទី រសៀល តាមរយៈលិខិតលេខ ៣០២ កប/អក/វក/លកអ.។ នៅថ្ងៃដដែលនោះ ភាគីទាំងពីរបានទទួលការជូនដំណឹងអំពីលិខិតអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ភាគីនិយោជកមានវត្តមាននៅថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ចំណែកឯ ភាគីកម្មករនិយោជិតវិញ មានតែមន្ត្រីសម្ព័ន្ធសជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចំនួន ២ នាក់ប៉ុណ្ណោះ ដែលបានមកចុះវត្តមាន និងចូលរួមសវនាការ។ ដោយឡែក មន្ត្រីសម្ព័ន្ធសហជីព ទាំង ២ នាក់នេះ បានអះអាងថា ពួកគាត់មិនមែនជាកម្មករនិយោជិតដែលជាភាគីដើមបណ្តឹងផ្ទាល់នោះទេ ហើយក៏ មិនមានសិទ្ធិតំណាងឱ្យភាគីកម្មករនិយោជិតនោះដែរ ពួកគាត់គ្រាន់តែមកអម នៅក្នុងសវនាការអាជ្ញាកណ្តាលតែប៉ុណ្ណោះ។ អ្នកដែលជាដើមបណ្តឹង គឺមានកម្មករនិយោជិត ចំនួន ៣៣ នាក់ ដោយពួកគាត់បានផ្ទេរសិទ្ធិទៅឱ្យតំណាងកម្មករនិយោជិត ចំនួន ៣ នាក់ ដែលមានឈ្មោះ ១.ជុំ សុខជា, ២. យ៉ែម ស៊ីណាត និងទី៣. ខាន់ ថួម។ នៅថ្ងៃសវនាការនោះ មន្ត្រីសម្ព័ន្ធសហជីពបានព្យាយាមទាក់ទងទៅតំណាងកម្មករនិយោជិតទាំង ៣ នាក់ ខាងលើ នេះដែរ ប៉ុន្តែពួកគាត់មិនទទួលទូរសព្ទ។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ២៧/១៨ កប/អក/លបវ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០១៨ ដែលមានកម្មករនិយោជិត ចំនួន ៣ នាក់ គឺ ១. ជុំ សុខជា, ២. យ៉ែម ស៊ីណាត និង៣. ខាត់ ថួម ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន រូ ស៊ីង ហ្គាម៉ែន (សាខាទី១) ក្នុងការដោះស្រាយវិវាទការងាររួម។ លើពីនេះ នៅថ្ងៃសវនាការ វេលាម៉ោង ៣ និង ២០ នាទី រសៀល មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានទាក់ទងតាមទូរសព្ទទៅកម្មករនិយោជិតឈ្មោះ ជុំ សុខជា ដែលជាអ្នកតំណាងភាគីកម្មករនិយោជិត ឱ្យមកចូលរួមសវនាការ ប៉ុន្តែ គាត់បានឆ្លើយតបថា គាត់មិនមកសវនាការទេ ព្រោះគាត់ជាប់រវល់បុណ្យនៅស្រុកកំណើតរបស់គាត់ គាត់ក៏បានដឹងអំពីសវនាការដែរ តែគាត់បានឱ្យលោក ស៊ាង យ៉ូត មន្ត្រីសម្ព័ន្ធសហជីពទៅជំនួស។ ហេតុនេះ នៅថ្ងៃសវនាការអាជ្ញាកណ្តាល គឺមិនមានវត្តមានរបស់អ្នកតំណាងភាគីកម្មករនិយោជិតទាំង ៣ នាក់ ឬកម្មករនិយោជិតនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន នៅក្នុងសវនាការនោះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា ដូចខាងក្រោម ៖

THE ARBITRATION COUNCIL

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ របស់នាយកក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន ផ្ទេរសិទ្ធិជូន លោក តាំង ម៉េង និងលោក ជូ ចាន់ស័ក។

២- បណ្ណពន្ធប៉ាតង់ឆ្នាំ២០១៨ របស់ក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន លេខ PTL2018012170 អពដ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨។

៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន លេខ MOC-៣៥៦៤១៩២៦ ពណ.ចបព ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧។

៤- លិខិតលេខ ០០៨៦ ពណ.ចបព ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងពាណិជ្ជកម្ម ជម្រាបមក អភិបាលក្រុមហ៊ុន រូ ស៊ីង ហ្គាម៉ែន ស្តីពីករណីសុំពង្រីកទីតាំងផលិតកម្ម។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន សាខាកាត់ដេរ រូស៊ីង ចុះទិដ្ឋាការលេខ ០០៧ កប/អក/អធក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ដោយនាយកដ្ឋានអធិការកិច្ចការងារ។

៦- លិខិតចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ របស់នាយកក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) គោរពជូន ប្រធាននាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការជូនដំណឹង កាត់បន្ថយកំលាំងពលកម្ម ចំនួន ២១១ នាក់ ដោយបែងចែកជា ៣ វគ្គ។

៧- លិខិតចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ របស់នាយកក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) គោរពជូន ប្រធាននាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការជូនដំណឹង កាត់បន្ថយកំលាំងពលកម្ម ចំនួន ១៥០ នាក់។

៨- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងនិយោជកនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨។

៩- លិខិតចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់នាយកក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការជូនដំណឹង កាត់បន្ថយកំលាំងពលកម្ម ចំនួន ២២០ នាក់។

១០- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងនិយោជកនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨។

១១- កំណត់ហេតុស្តីពីការព្រមព្រៀងលើការចុះកិច្ចសន្យាការងារមានកំណត់ថិរវេលា FDC សម្រាប់កម្មករ និយោជិតធ្វើការលើសពី ២ ឆ្នាំ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥។

ARBITRATION COUNCIL

១២- បញ្ជីឈ្មោះកម្មករនិយោជិតយល់ព្រមអនុវត្តតាមខ្លឹមសាររួមក្នុងកំណត់ហេតុស្តីពីការព្រមព្រៀងលើការចុះកិច្ចសន្យាការងារមានកំណត់ថិរវេលា(FDC) សម្រាប់កម្មករ និយោជិតដែលធ្វើការលើសពី ២ ឆ្នាំ ឡើងទៅ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

- លិខិតចាត់តាំងលោក ស៊ាង យ៉ុត លេខ ០៣៥/១៨ .វិវាទ ជាមន្ត្រីដោះស្រាយវិវាទ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីអមសម្របសម្រួលលើករណីដោះស្រាយវិវាទក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន សាខាទី១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) លេខ ១០៥៨ កប/អក/វក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន (សាខាទី១) ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០១៨។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន រូ ស៊ីង ហ្គាម៉ែន (សាខាទី១) លេខ ២៧/១៨ កប/អក/លបវ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣០១ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១១រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣០២ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១១រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨។។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងមិនបានមកចូលរួមសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានភាគីកម្មករនិយោជិតដែលជាភាគីដើមបណ្តឹង?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ ក្រុមអាជ្ញាកណ្តាលត្រូវ

*អញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត ។"* ។

ប្រការ ២០ នៃប្រកាសខាងលើដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ។"* ។

ប្រការ ២១ នៃប្រកាសខាងលើដដែលនេះ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់ ។"* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់ ។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន ។"* ។

យោងតាមប្រការ ១៨ ប្រការ ២០ និងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ខាងលើ និងវិធាន ៤.៧ នៃឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនៃវិវាទមានកាតព្វកិច្ចត្រូវចូលរួមរាល់កិច្ចប្រជុំទាំងអស់ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបកស្រាយដែរថា មានលក្ខខណ្ឌបីដែលត្រូវបំពេញដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ គឺ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣០/០៥-មូរៀ, លេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ីម និង វើ ៣, លេខ ៩៥/ ០៨-យ៉ុង វ៉ាទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិល សិន, លេខ ០៩/ ០៩-នីមប៊ីសថិចថាយ៍, លេខ ០១/១០-ខិននីតិច, លេខ ៣០/១០-ក្លូប័ល អាប៉ារែល, លេខ ១៣០/១៣-យែន ធើរេន អ៊ីកែរីល, លេខ ១៦៧/១៣-ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល និងលេខ ២៧០/១៣-៨ ស្តារ ស្តតវែរ)* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗ ខាងលើដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរឬទេ?

**លក្ខខណ្ឌទី ១- ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ**

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងឱ្យមកចូលរួមសវនាការអាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ តាមរយៈលិខិតលេខ ៣០២ កប/អក/វក/លកអ. ចុះថ្ងៃ០៣ ខែធ្នូ ឆ្នាំ២០១៨ ដោយមានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរសព្ទ និងទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ ភាគីតំណាងកម្មករនិយោជិតក៏បានទទួលនូវលិខិតអញ្ជើញសវនាការនេះដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញ និងជូនដំណឹងយ៉ាងត្រឹមត្រូវអំពី កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការអាជ្ញាកណ្តាល។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២- ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា “*ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*” នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន ១-វត្តមាននៅក្នុងសវនាការ និង ២-ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

បន្ថែមលើនេះ ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា៖ *“ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ។”* ។

នៅក្នុងសំណុំរឿងនេះ អ្នកតំណាងភាគីកម្មករនិយោជិតដែលជាភាគីដើមបណ្តឹង មិនបានបង្ហាញវត្តមាននៅថ្ងៃសវនាការអាជ្ញាកណ្តាលនោះទេ គឺមានន័យថា មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ និងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារនៃប្រការ ២១ នៃប្រកាសលេខ ០៩៩ ទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការទេ។ ហេតុនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ៣- ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅថ្ងៃសវនាការ វេលាម៉ោងប្រហែល ៣ និង ២០ នាទី រសៀល មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទាក់ទងតាមរយៈទូរសព្ទទៅតំណាងកម្មករនិយោជិតម្នាក់ឈ្មោះ ជុំ សុខជា ដើម្បីសួរនាំគាត់ថា

តើគាត់មកចូលរួមសវនាការអាជ្ញាកណ្តាលដែរ ឬទេ? លោក ជុំ សុខជា បានឆ្លើយតបថា គាត់មិនបានមកចូលរួមទេ ព្រោះជាប់រវល់បុណ្យនៅស្រុកកំណើត។ ករណីនេះ អ្នកតំណាងភាគីកម្មករនិយោជិតមិនបានស្នើសុំមកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីលើកពេលសវនាការនោះទេ ដោយមូលហេតុខាងលើនេះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានផ្តល់ហេតុផល សម្រាប់អវត្តមានរបស់ខ្លួននោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្និដ្ឋានថា អ្នកតំណាងភាគីកម្មករនិយោជិតមិនបានផ្តល់មូលហេតុត្រឹមត្រូវ សម្រាប់ការមិនបង្ហាញខ្លួននេះឡើយ។ ដូចនេះ លក្ខខណ្ឌទី ៣ ត្រូវបានបំពេញ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ ត្រូវបានបំពេញ។

នៅក្នុងសំណុំរឿងនេះ ភាគីតំណាងកម្មករនិយោជិត គឺជាដើមបណ្តឹង។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កាតព្វកិច្ចរបស់ភាគីដើមបណ្តឹង និងភាគីចុងបណ្តឹងនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញា-កណ្តាល គឺត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗ ដែលពាក់ព័ន្ធនឹងចំណុចវិវាទសម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួនពីការទាមទារ ឬការចោទប្រកាន់ពីសំណាក់ដើមបណ្តឹង ដែលកាតព្វកិច្ចនេះ ជាទូទៅ នឹងត្រូវកើតឡើងក្រោយពេលដែលដើមបណ្តឹងបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុនសិន។

ក្នុងសំណុំរឿងនេះ ដើមបណ្តឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ លើសពីនេះ ភាគីដើមបណ្តឹង ក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ដើមបណ្តឹងបានបោះបង់ចោលការទាមទាររបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបន្តដំណើរការអាជ្ញាកណ្តាលនោះទេ។

ផ្អែកតាមវិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និងប្រកាសលេខ ០៩៩ ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៤៦/១៨-រូ ស៊ីង ហ្គាម៉ែន (សាខាទី១) ដោយចេញសេចក្តីបង្គាប់។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

**សម្រេច**

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ០៤៦/១៤ - រូស៊ីង ហ្គាម៉ែន (សាខាទី១)។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **អ៊ុខ សុទ្ធី**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ឆួន ស៊ីផាន់**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ----------------------------------------